# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

២០១៦

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧០៦ MIH / 2016

# ប្រកាស
## ស្តីពីការកែសម្រួលសមាសភាព
## ក្រុមប្រឹក្សាស្តង់ដារជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១៖** ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាស្តង់ដារជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២- ឯកឧត្តម | ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម | អ៊ឹក ប្រជា | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- លោក | ហ៊ាន វណ្ណហាន | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥- លោកឧសថបណ្ឌិត | ហេង ប៊ុនគៀត | តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៦- ឯកឧត្តម | ឡៅ ហ៊ុម | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

៧- ឯកឧត្តម ទា ច័ន្ទលីដា តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៨- ឯកឧត្តមបណ្ឌិត យិត បុណ្ណា តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៩- ឯកឧត្តម ហ៊ែល ចំរើន តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១០- ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវត្ត តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
១១- លោកបណ្ឌិត ប៊ុន ណារិទ្ធ តំណាងក្រសួងរ៉ែ និងថាមពល សមាជិក
១២- លោក កើត ពុទ្ធរី តំណាងក្រសួងទេសចរណ៍ សមាជិក
១៣- លោក ជា ស៊ីណា តំណាងក្រសួងបរិស្ថាន សមាជិក
១៤- លោកបណ្ឌិត ហាន វីរៈ តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សមាជិក
១៥- លោកស្រីបណ្ឌិត សៀង ហ៊ុយ តំណាងរាជបណ្ឌិត្យសភាកម្ពុជា សមាជិក
១៦- លោក ជ័យ ថាវី តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សមាជិក
១៧- លោកបណ្ឌិត គឹម សុជា តំណាងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សមាជិក
១៨- លោកសាស្ត្រាចារ្យបណ្ឌិត សុក គន្ធី តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម សមាជិក
១៩- លោកឧកញ៉ា តែ តាំងប៉ តំណាងសម្ព័ន្ធ សមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា សមាជិក
២០- លោក ឡុញ គឹមអៀន តំណាងសភាពាណិជ្ជកម្មកម្ពុជា សមាជិក
២១- លោក ហេង ហ៊ាង តំណាងសមាគមឧស្សាហកម្មតូច និងមធ្យមរាជធានីភ្នំពេញ សមាជិក
២២- លោក ម៉ុក ម៉ែ តំណាងសមាគមអ្នកប្រើប្រាស់ សមាជិក
២៣- លោក ចាន់ សុផា តំណាងវិទ្យាស្ថានស្តង់ដារកម្ពុជា លេខាធិការ
២៤- លោក ឆេង ឧត្តរា តំណាងវិទ្យាស្ថានស្តង់ដារកម្ពុជា លេខាធិការ
២៥- លោក ចឹក វិចិត្រ តំណាងវិទ្យាស្ថានស្តង់ដារកម្ពុជា លេខាធិការ

**ប្រការ២៖** ក្រុមប្រឹក្សាស្តង់ដារជាតិ មានភារកិច្ចដូចទៅ៖

- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលស្តង់ដារជាតិណាមួយ
- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលសញ្ញាស្តង់ដារជាតិណាមួយ
- កំណត់អំពីស្តង់ដារស្ម័គ្រចិត្ត ឬស្តង់ដារបេញ្ជា ឬសញ្ញាស្តង់ដារ
- ជូនយោបល់ដល់រដ្ឋមន្ត្រីអំពីអាទិភាព និងគោលនយោបាយនៃស្តង់ដារូបនីយកម្ម កម្មវិធីផែនការ គម្រោង និងសកម្មភាពនានា ដើម្បីជានាឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត
- ជូនយោបល់ និងលើកអនុសាសន៍ជូនរដ្ឋមន្ត្រី អំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃស្តង់ដារ សម្រាប់ផលិតផលដំណើរការអនុវត្តការធ្វើតេស្ត និងសេវាកម្ម និងសម្រេចយល់ព្រមលើកម្មវិធីផែនការ គម្រោង និងសកម្មភាពនានា សំដៅជំរុញប្រសិទ្ធភាព និងការអភិវឌ្ឍឧស្សាហកម្ម និងសម្រាប់ការពារ អ្នកប្រើប្រាស់ តាមរយៈសកម្មភាពស្តង់ដារូបនីយកម្ម
- ណែនាំវិទ្យាស្ថានអំពីលក្ខណវិនិច្ឆ័យ និងនីតិវិធីដែលទាក់ទិនដល់ការរៀបចំ ការសម្រេចយល់ព្រម ការទទួលយក និងការជ្រើសរើសស្តង់ដារ
- រៀបចំបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា និង
- បំពេញមុខងារដទៃទៀតទៅតាមការកំណត់ ឬតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ [illegible]៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ៣ ៖** សមាជិកក្រុមប្រឹក្សាស្តង់ដារជាតិ ត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ។ សម័យប្រជុំក្រុមប្រឹក្សាអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមចំនួនលើសពីពាក់កណ្តាលនៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សាត្រូវប្រព្រឹត្តទៅដោយមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកវត្តមានក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា លើកលែងតែការពិនិត្យ សម្រេច ឬការកែសម្រួលស្តង់ដារជាតិ ដែលត្រូវអនុម័តតាមមតិបីភាគបួននៃចំនួនសមាជិកចូលរួមប្រជុំ។ នៅពេលប្រធានអវត្តមាន ក្រុមប្រឹក្សាស្តង់ដារជាតិ អាចធ្វើការប្រជុំទៅបានក្រោមការដឹកនាំរបស់អនុប្រធានក្រុមប្រឹក្សា ឬសមាជិកតំណាងណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤ ៖** ក្រុមប្រឹក្សាស្តង់ដារជាតិ អាចបង្កើតគណៈកម្មការបច្ចេកទេសស្តង់ដារ អនុគណៈកម្មការបច្ចេកទេសស្តង់ដារ ឬក្រុមការងារស្តង់ដារទៅតាមវិស័យនីមួយៗបាន ដើម្បីជួយបំពេញមុខងារ និងភារកិច្ច ឬសម្រាប់គោលបំណងផ្សេងទៀតដែលកើតឡើង ឬដែលទាក់ទិនដល់មុខងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ៥ ៖** ក្រុមប្រឹក្សាស្តង់ដារជាតិ អាចធ្វើការកែសម្រួល ឬលុបចោលសេចក្តីសម្រេចណាមួយដែលគណៈកម្មការបច្ចេកទេសស្តង់ដារបានអនុម័ត។

**ប្រការ៦ ៖** ក្នុងករណីសមាជិកក្រុមប្រឹក្សាស្តង់ដារជាតិណាម្នាក់អវត្តមាននៅក្នុងកិច្ចប្រជុំនោះ មានន័យថាសមាជិករូបនោះបានឯកភាពទៅលើអ្វីដែលកិច្ចប្រជុំអនុម័ត។

**ប្រការ៧ ៖** ប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ ត្រូវទទួលខុសត្រូវលើសកម្មភាពស្តង់ដារូបនីយកម្ម ចំពោះមុខរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៨ ៖** ប្រកាសលេខ ១៤១ MIH/2014 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៩ ៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**និងជាប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៩
  «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com